**សេចក្ដីជូនដំណឹងអំពីការពិគ្រោះថ្លៃ(ផ្សព្វផ្សាយឡើងវិញ)**

**សហគមន៍កសិកម្មសំបូរមានជ័យ**

**មានបំណងទិញប្រព័ន្ធសូឡាបូមទឹក និងម៉ូទ័របញ្ជូន**

១. សហគមន៍កសិកម្ម របស់យើងខ្ញុំបានទទួលមូលនិធិ ពីគម្រោងពិពិធកម្មសិកម្មកម្ពុជា ដែលផ្ដល់ហិរញ្ញប្បទាន ដោយសមាគមអភិវឌ្ឍន៍អន្តរជាតិ(IDA) ដើម្បីធ្វើការទូទាត់នៅក្រោមកិច្ចសន្យាសម្រាប់ការផ្គត់ផ្គង់ប្រព័ន្ធសូឡាបូមទឹក និងម៉ូទ័របញ្ជូន កិច្ចសន្យាលេខ ២.២។

២. ទំនិញនឹងត្រូវបានប្រគល់ទទួលក្នុងរយៈពេល ៦០ ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាកិច្ចសន្យា។

៣. អ្នកផ្គត់ផ្គង់ទាំងឡាយដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានចំណាប់អារម្មណ៍ នឹងត្រូវបានអញ្ជើញមកទទួលឯកសារពិគ្រោះថ្លៃ ដោយឥតគិតថ្លៃ នៅអាសយដ្ឋានបង្ហាញខាងក្រោម ដើម្បីផ្គត់ផ្គង់ទំនិញដែលបានរៀបរាប់ក្នុងទម្រង់ទី២៖ លក្ខណបច្ចេកទេស ដែលបានភ្ជាប់មកជាមួយឯកសារពិគ្រោះថ្លៃនេះ។
**សហគមន៍កសិកម្មសំបូរមានជ័យ អាស័យដ្ឋាន ភូមិសំបូរ ឃុំសូភាស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម លេខទូរសព្ទ ០៧៧ ៩៩ ៦៧ ៦៨។ អ្នកផ្គត់ផ្គង់អាចទាក់ទង លោក ភេន វុទ្ធី គូនាទីជាជំនួយការលទ្ធកម្ម តាមរយៈលេខទូរសព្ទ ០៩៩ ៣០៥ ៥៤២ ដើម្បីទទួលឯកសារពិគ្រោះ។**

៤. ដើម្បីជាលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងអាចទទួលយកបាន អ្នកពិគ្រោះថ្លៃត្រូវ៖
ជាពាណិជ្ជករ ក្រុមហ៊ុនឯកជន ឬអាជីវករក្នុងសហគមន៍ ដែលមានអត្តសញ្ញាណសំគាល់ច្បាស់លាស់ដូចជា អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងប័ណ្ណប៉ាតង់ប្រចាំឆ្នាំ (នៅមានសុពលភាព) ហើយអាចផ្គត់ផ្គង់ទំនិញតាមតម្រូវការ និងលក្ខណៈបច្ចេកទេសដែលបានបញ្ជាក់ក្នុងឯកសារពិគ្រោះថ្លៃ។ អ្នកផ្គត់ផ្គង់ដែលត្រូវបានកំណត់ថាពាក់ព័ន្ធនឹងការក្លែងបន្លំ អំពើពុករលួយ និងអំពើឃុបឃិត ហើយស្ថិតក្នុងបញ្ជីហាមឃាត់ ក្នុងអំឡុងពេលនៃការពិគ្រោះថ្លៃ នឹងមិនមានសិទ្ធិចូលរួមពិគ្រោះថ្លៃឡើយ។

៥. សំណើពិគ្រោះថ្លៃ និងតម្លៃទំនិញ ក្នុងសំណើពិគ្រោះថ្លៃ ត្រូវមានសុពលភាព និងជាតម្លៃថេរសម្រាប់រយៈពេល៦០ថ្ងៃ បន្ទាប់ពីថ្ងៃផុតកំណត់នៃការទទួលសំណើពិគ្រោះថ្លៃ។

៦. តម្លៃសំណើពិគ្រោះថ្លៃត្រូវរួមបញ្ចូលនូវ ពន្ធអាករនានា ការដឹកជញ្ជូន ការធានារ៉ាប់រង និងចំណាយផ្សេងទៀត ដើម្បីប្រគល់ទំនិញដល់ទីកន្លែងប្រគល់ចុងក្រោយ។

៧. សំណើពិគ្រោះថ្លៃមិនត្រូវបានអនុញ្ញាតឱ្យមានការផ្លាស់ប្ដូរឬកែប្រែឡើយ។

៨. ការធានាលើទំនិញទៅតាមប្រភេទនៃមុខទំនិញនីមួយៗ ដូចមានរៀបរាប់ក្នុងទម្រង់ទី២៖ យថាប្រភេទ និងលក្ខណៈបច្ចេកទេស ។

៩. សំណើពិគ្រោះថ្លៃច្បាប់ដើមត្រូវចុះហត្ថលេខាដោយអ្នកពិគ្រោះថ្លៃ ឬអ្នកដែលបានទទួលសិទ្ធិពេញលេញដើម្បីចុះហត្ថលេខាជំនួសមុខឱ្យអ្នកពិគ្រោះថ្លៃ។ អ្នកពិគ្រោះថ្លៃត្រូវដាក់សំណើពិគ្រោះថ្លៃក្នុងស្រោមសំបុត្រមួយបិទជិត ហើយបញ្ជូនទៅតាមអាសយដ្ឋានដូចមានបញ្ជាក់នៅក្រោមឱ្យបានមុនឬត្រឹមថ្ងៃទី២៨ ខែ០៨ ឆ្នាំ២០២៥ ម៉ោង ........៥:០០ ល្ងាច.......... នៅអាសយដ្ឋានដូចខាងក្រោម៖
**សហគមន៍កសិកម្មសំបូរមានជ័យ អាស័យដ្ឋាន ភូមិសំបូរ ឃុំសូភាស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម លេខទូរសព្ទ ០៧៧ ៩៩ ៦៧ ៦៨។ អ្នកផ្គត់ផ្គង់អាចទាក់ទង លោក ភេន វុទ្ធី គូនាទីជាជំនួយការលទ្ធកម្ម តាមរយៈលេខទូរសព្ទ ០៩៩ ៣០៥ ៥៤២ ។**
សំណើពិគ្រោះដែលដាក់មកយឺតនឹងត្រូវបដិសេធ។ សំណើពិគ្រោះថ្លៃនឹងបើកជាសាធារណៈភ្លាមៗបន្ទាប់ពីកាលបរិច្ឆេទផុតកំណត់ឈប់ទទួលសំណើពិគ្រោះថ្លៃ នៅទីតាំងដែលបានបញ្ជាក់ខាងក្រោម នៅចំពោះមុខតំណាងអ្នកពិគ្រោះថ្លៃ ដែលអាចចូលរួមដោយផ្ទាល់។

Scanned with CamScanner

១០.គ្រប់សំណើពិគ្រោះថ្លៃត្រូវភ្ជាប់មកជាមួយនូវ លិខិតប្រកាសស្តីពីការធានាការពិគ្រោះថ្លៃ ដូចមានចែងក្នុងឯកសារពិគ្រោះថ្លៃ។ សំណើពិគ្រោះថ្លៃដែលមិនភ្ជាប់មកជាមួយនូវ លិខិតប្រកាសស្តីពីការធានាការពិគ្រោះថ្លៃត្រូវបដិសេធ។

១១.សំណើពិគ្រោះថ្លៃដែលត្រូវបានវាយតម្លៃដោយធ្វើការកែតម្រូវការភ័ន្តច្រឡំនៃការគណនានានា ត្រូវបានធ្វើឡើយលើមូលដ្ឋានដូចខាងក្រោម៖

(ក) នៅពេលដែលមានការខុសគ្នារវាងចំនួនទឹកប្រាក់ជាតួលេខ និងចំនួនទឹកប្រាក់ជាអក្សរ នោះចំនួនទឹកប្រាក់ជាអក្សរនឹងយកជាបានការ។

(ខ) នៅពេលដែលមានការខុសគ្នារវាងថ្លៃឯកតា និងតម្លៃសរុបនៃមុខទំនិញនីមួយៗ ដែលបានមកពីផលគុណថ្លៃឯកតានឹងបរិមាណ នោះថ្លៃឯកតានឹងយកជាគោល។

ប្រសិនបើអ្នកពិគ្រោះថ្លៃបដិសេធមិនទទួលយកការកែតម្រូវ សំណើពិគ្រោះថ្លៃរបស់គេត្រូវបានបដិសេធ ហើយលិខិតប្រកាសស្តីពីការធានាការពិគ្រោះថ្លៃត្រូវបានអនុវត្ត។

១២.សហគមន៍កសិកម្ម ត្រូវសម្រេចប្រគល់កិច្ចសន្យាទៅឱ្យអ្នកពិគ្រោះថ្លៃណាដែលសំណើពិគ្រោះថ្លៃរបស់គេត្រូវបានកំណត់ថាមានការឆ្លើយតបច្រើន ស្របទៅតាមបទដ្ឋាន និងលក្ខណៈបច្ចេកទេស និងបានដាក់តម្លៃពិគ្រោះថ្លៃដែលត្រូវបានវាយតម្លៃថាទាបសមស្របជាងគេ។

១៣. ករណីពិបាកណាមួយ ក្នុងការទទួលយកឯកសារពិគ្រោះថ្លៃ អ្នកមានចំណាប់អារម្មណ៍ចង់ចូលរួមពិគ្រោះថ្លៃទាំងអស់ អាចជូនដំណឹងជាលាយលក្ខអក្សរអំពីករណីពិបាកនោះជូន **ឆេង ថុង** ជាប្រធានក្រុមប្រឹក្សាភិបាល **សហគមន៍កសិកម្ម ទូរសព្ទលេខ ០៧៧ ៩៩ ៦៧ ៦៨ អាស័យដ្ឋាន ភូមិសំបូរ ឃុំសូភាស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម** និងចតចម្លងផ្ញើជូនទៅ៖

ក្រុមរដ្ឋបាលគ្រប់គ្រងទុនវិនិយោគបន្ថែម នៃគម្រោងពិពិធកម្មកសិកម្មកម្ពុជា ដែលមានអាសយដ្ឋាននៅជាន់ផ្ទាល់ដីនៃនាយកដ្ឋានសហប្រតិបត្តការអន្តរជាតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាយសដ្ឋាន៖# ២០០ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

១៤.បន្ទាប់ពីការសម្រេចប្រគល់កិច្ចសន្យាត្រូវបានប្រកាស អ្នកពិគ្រោះថ្លៃដែលបរាជ័យមានសិទ្ធិស្នើសុំឱ្យមានការពន្យល់ ដើម្បីដឹងច្បាស់ពីមូលហេតុនៃការបរាជ័យនៃសំណើពិគ្រោះថ្លៃរបស់ខ្លួន ហើយគណៈកម្មការលទ្ធកម្មរបស់សហគមន៍កសិកម្ម មានកាតព្វកិច្ចផ្តល់ការពន្យល់នេះ។ ការសង្ងាត់ផ្ទាល់ខ្លួនរបស់អ្នកពិគ្រោះថ្លៃត្រូវបានរក្សាជាការសង្ងាត់មិនឱ្យភាគីផ្សេងទៀតបានដឹងឡើយ។

១៥.បណ្តឹងតវ៉ាត្រូវបញ្ជូនទៅប្រធានក្រុមប្រឹក្សាភិបាលនៃសហគមន៍កសិកម្ម ។ ប្រធានក្រុមប្រឹក្សាភិបាលនឹងធ្វើការអង្កេតលើមូលដ្ឋាននៃកាតវ៉ា និងធ្វើការឆ្លើយតបជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេល៧ថ្ងៃប្រតិទិន បន្ទាប់ពីទទួលបានបណ្តឹងតវ៉ានេះ លើកលែងតែក្នុងករណីការតវ៉ា ដែលបានទទួលក្នុងអំឡុងពេលវាយតម្លៃ ។ ការតវ៉ាដែលទទួលបានក្នុងអំឡុងពេលវាយតម្លៃសំណើពិគ្រោះ ត្រូវបានពិនិត្យមើលដោយគណកម្មការលទ្ធកម្មនៃសហគមន៍កសិកម្ម ហើយការឆ្លើយតប នឹងធ្វើឡើងបន្ទាប់ពីការវាយតម្លៃត្រូវបានបញ្ចប់ប៉ុណ្ណោះ។

ក្នុងករណីការឆ្លើយតបរបស់ប្រធានក្រុមប្រឹក្សាភិបាលនៃសហគមន៍កសិកម្ម មិនបំពេញតាមបំណងរបស់អ្នកពិគ្រោះថ្លៃចាញ់ ឬពុំមានការឆ្លើយតបណាមួយត្រូវបានធ្វើឡើងនោះទេ នោះអ្នកតវ៉ាត្រូវដាក់បណ្តឹងតវ៉ា ទៅកាន់ក្រុមរដ្ឋបាលគ្រប់គ្រងទុនវិនិយោគបំពេញបន្ថែម។ ក្រុមរដ្ឋបាលគ្រប់គ្រងទុនវិនិយោគបំពេញបន្ថែមត្រូវឆ្លើយតបការតវ៉ាក្នុងរយៈពេល ៧ ថ្ងៃប្រតិទិន។ ករណីនេះមិនបណ្តាលឱ្យមានការបាត់បង់សិទ្ធិរបស់អ្នកពិគ្រោះថ្លៃ ចំពោះការប្តឹងបន្តណាមួយផ្សេងទៀតដែលអ្នកពិគ្រោះថ្លៃអាចជ្រើសរើសនោះទេ។

Scanned with CamScanner

១៦.គោលការណ៍របស់សមាគមអភិវឌ្ឍន៍អន្តរជាតិតម្រូវឱ្យអ្នកខ្ចី (រួមទាំងអ្នកទទួលផលពីប្រាក់កម្ចីពីធនាគារ) អ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ អ្នកទទួលការ និងភ្នាក់ងាររបស់ពួកគេ (ទោះជាប្រកាស ឬមិនប្រកាស) អ្នកទទួលការបន្ត អ្នកប្រឹក្សាបន្ទាប់ អ្នកផ្តល់សេវា ឬអ្នកផ្គត់ផ្គង់ និងបុគ្គលិកណាមួយ ត្រូវគោរពឱ្យបានហ្មត់ចត់តាមស្តង់ដារ នៃក្រមសីលធម៌វិជ្ជាជីវៈ ក្នុងអំឡុងពេលអនវត្តកិច្ចលទ្ធកម្មនិងក្នុងការអនុវត្តកិច្ចសន្យាដែលផ្តល់ហិរញ្ញប្បទានដោយសមាគមអភិវឌ្ឍន៍អន្តរជាតិ។

១៧.អ្នកទទួលការ អ្នកផ្គត់ផ្គង់ និងអ្នកផ្តល់សេវាទាំងអស់ត្រូវអនុញ្ញាតឱ្យសមាគមអភិវឌ្ឍន៍អន្តរជាតិ និង/ឬអ្នកដែលត្រូវបានតែងតាំងដោយសមាគមអភិវឌ្ឍន៍អន្តរជាតិត្រួតពិនិត្យ ការដ្ឋាន គណនី និងឯកសារទាំងអស់ដែលទាក់ទងនឹងការអនុវត្តកិច្ចសន្យា ក៏ដូចជាសំណើពិគ្រោះថ្លៃផងដែរ ហើយគណនី និងឯកសារទាំងអស់នេះត្រូវបានធ្វើសវនកម្មដោយសវនករដែលត្រូវបានតែងតាំងដោយសមាគមអភិវឌ្ឍន៍អន្តរជាតិ ប្រសិនបើត្រូវបានស្នើសុំដោយសមាគមអភិវឌ្ឍន៍អន្តរជាតិ ។

ប្រធានក្រុមប្រឹក្សាភិបាលនៃសហគមន៍កសិកម្ម

ហត្ថលេខា________

ឈ្មោះ________

Scanned with CamScanner